**គ.ស.ធ.ឱ.**មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ស.ឱ.** សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធានរបស់ គ.ស.ធ.ឱ.

**មាត្រា១៨.-**

ថវិកាសម្រាប់ដំណើរការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឱ.** ត្រូវគាំទ្រដោយថវិកាជាតិក្នុងគម្រោងថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.ស.ធ.ឱ.** មានសិទ្ធិទទួល ប្រើប្រាស់ និងចាត់ចែងធនធាននិងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់ជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

នៃអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កត្តិក ឆ្នាំ ២០២១
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់
គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.)

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ.



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១.**_ បំពាក់មេដាយ**ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ១២៣រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តព្រឹក្សានិងវត្តសំរោងវ័ត្ត ឃុំពេជសារ ស្រុកកោះអណ្តែត ខេត្តតាកែវ កន្លងមក ដូចមានរាយនាមខាងក្រោមៈ

ក-មេដាយ**មាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | ព្រះគ្រូសីលសំវរោ | គួន ស្តៅ | ព្រះចៅអធិការវត្តសំរោងវ័ត្ត |
| ២- | ព្រះគ្រូបញ្ញាបទិបោ | ព្រុំ ថាន់ | ព្រះចៅអធិការវត្តពោធិវង្សលើ |
| ៣- | ព្រះគ្រូបញ្ញាសិរិបណ្ឌតោ | អ៊ឹម សុវណ្ណ | ព្រះចៅអធិការវត្តបទុមមង្គល(ព្រៃបាយ) |
| ៤- | ព្រះតេជគុណ | ព្រីន ឆាង | សប្បុរជននៅរាជធានីភ្នំពេញ |
| ៥- | ព្រះតេជគុណ | ហាន ចិន | សប្បុរជននៅរាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៦- | ព្រះតេជគុណ | អ៊ិន រ៉ាយុ | សប្បុរជននៅរាជធានីភ្នំពេញ |
| ៧- | ព្រះតេជគុណ | កេ សុខេន | សប្បុរជននៅរាជធានីភ្នំពេញ |
| ៨- | ព្រះតេជគុណ | យុន សំបុត្រ | សប្បុរជននៅរាជធានីភ្នំពេញ |
| ៩- | ព្រះតេជគុណ | ជន់ សម្បត្តិ | សប្បុរជននៅរាជធានីភ្នំពេញ |
| ១០- | ព្រះតេជគុណ | គង់ ប្រុស | សប្បុរជននៅរាជធានីភ្នំពេញ |
| ១១- | ព្រះតេជគុណ | គង់ វិសាល | សប្បុរជននៅខេត្តកណ្ដាល |
| ១២- | ឯកឧត្តម | ពៅ សុខ | ទីប្រឹក្សាសម្ដេចតេជោនាយករដ្ឋមន្ត្រី |
| ១៣- | លោក | ង៉ែត ឯន | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៤- | លោក | យុន សោភ័ណ្ឌ | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៥- | លោក | ប៊ុន សុធា | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៦- | លោក | អ៊ឹម ម៉េង | សប្បុរជននៅខេត្តតាកែវ |
| ១៧- | ឧបាសក | ង៉ែត សាំ | សប្បុរជននៅខេត្តតាកែវ |
| ១៨- | ឧបាសិកា | អន លាង | សប្បុរជននៅខេត្តតាកែវ |
| ១៩- | លោក | ប៊ុម វ៉ែន | ស្មៀនឃុំពេសារ |
| ២០- | អ្នកស្រី | រិត ខេមរាពីសី | សប្បុរជននៅរាជធានីភ្នំពេញ |
| ២១- | អ្នកស្រី | វ៉ាត លក្ខិណា | សប្បុរជននៅរាជធានីភ្នំពេញ |
| ២២- | លោក | ព្រីង ឃឿន | សប្បុរជននៅរាជធានីភ្នំពេញ |
| ២៣- | អ្នកស្រី | អេងលី ព្រីង | សប្បុរជននៅរាជធានីភ្នំពេញ |

ខ-មេដាយ**ប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | លោក | ទុយ ស្រៀង | សប្បុរជននៅរាជធានីភ្នំពេញ |
| ២- | លោក | ហៅ គីនី | សប្បុរជននៅរាជធានីភ្នំពេញ |
| ៣- | លោក | អ៊ុំ វុទ្ធទី | សប្បុរជននៅរាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ៤- | លោក | សាយ សាវ៉ាន់ | សប្បុរជននៅរាជធានីភ្នំពេញ |
| ៥- | លោក | ឈិន ឌុន | សប្បុរជននៅរាជធានីភ្នំពេញ |
| ៦- | លោក | លាង ហុង | សប្បុរជននៅរាជធានីភ្នំពេញ |
| ៧- | លោក | យ៉យ បូវ៉ា | សប្បុរជននៅរាជធានីភ្នំពេញ |
| ៨- | លោក | មាស សុខគីម | សប្បុរជននៅរាជធានីភ្នំពេញ |
| ៩- | លោក | ផន ផាន់នូ | សប្បុរជននៅរាជធានីភ្នំពេញ |
| ១០- | លោក | លាង ស៊ីឡុង | សប្បុរជននៅរាជធានីភ្នំពេញ |
| ១១- | លោក | ម៉ៃ សំណាង | សប្បុរជននៅរាជធានីភ្នំពេញ |
| ១២- | លោក | ឌឹម បូរិន | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៣- | លោក | លី រដ្ឋា | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៤- | លោក | សែម សុភា | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៥- | លោក | ចែម សុខភិរុណ | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៦- | លោក | សាន ទីតូ | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៧- | លោក | នាង ស៊ីណាវ៉ាន់ | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៨- | លោក | ហាម វឿន | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៩- | លោក | ប៉ែន ថុល | មេឃុំរាមអណ្ដើក |
| ២០- | លោក | ហាម លាងឃីម | សប្បុរជននៅរាជធានីភ្នំពេញ |
| ២១- | លោក | គង់ សុធារក្ស | សប្បុរជននៅរាជធានីភ្នំពេញ |
| ២២- | លោក | ឃឹម ណារិទ្ធ | សប្បុរជននៅរាជធានីភ្នំពេញ |
| ២៣- | លោក | នាង ភារិទ្ធ | សប្បុរជននៅខេត្តកណ្ដាល |
| ២៤- | លោក | ឈួន ចិន្តា | សប្បុរជននៅរាជធានីភ្នំពេញ |
| ២៥- | លោក | ឡុង អុង | សប្បុរសជននៅខេត្តកំពង់ស្ពឺ |

| | | | |
|---|---|---|---|
| ២៦- | កញ្ញា | ប៉ុន មករា | សប្បុរជននៅរាជធានីភ្នំពេញ |
| ២៧- | អនុសេនីយ៍ឯក | យ៉ុម សុខគា | សប្បុរជននៅរាជធានីភ្នំពេញ |

គ-មេដាយ**សំរឹទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | លោក | ម៉ី សេន | មេភូមិពោន |
| ២- | លោក | យ៉ែម យីវ | មេភូមិពោធិ |
| ៣- | លោក | អ៊ុច សាំ | មេភូមិជន្ទល់មេឃ |
| ៤- | លោក | ទោះ ម៉ន | មេភូមិស្លែង |
| ៥- | លោក | ឈឹម វណ្ណា | មេប៉ុស្តិ៍រដ្ឋបាលឃុំពេជសារ |
| ៦- | លោក | សួន ថុង | អនុភូមិគោកខ្ពស់ |
| ៧- | លោកស្រី | ស៊ឹម យឿន | មេភូមិចុងអង្គរ |
| ៨- | លោក | ម៉ម ស្តើង | មេភូមិតាបស |
| ៩- | លោក | ឡាយ ញ៉ន | មេភូមិអង្គុញ |
| ១០- | លោក | កល់ ហៀង | មេភូមិគោកខ្ពស់ |
| ១១- | លោក | ពិន សុផល | មេភូមិទូលស្វាយ |
| ១២- | លោក | យឹម អាន | មេភូមិក្របាក់ |
| ១៣- | លោក | ប៉ាវ បូរ៉េត | សប្បុរជននៅខេត្តតាកែវ |
| ១៤- | លោក | ម៉ម សារ៉េត | សប្បុរជននៅខេត្តកំពង់ចាម |
| ១៥- | លោក | វ៉ែន លឹង | សប្បុរជននៅរាជធានីភ្នំពេញ |
| ១៦- | ឧបាសក | ប៉ុម ឡុង | អាចារ្យភូមិពេជសារ |
| ១៧- | ឧបាសក | កឹម កង | អាចារ្យភូមិពេជសារ |
| ១៨- | ឧបាសក | ចាន់ សេ | អាចារ្យភូមិពេជសារ |
| ១៩- | ឧបាសក | ចាន់ អុន | អាចារ្យភូមិពេជសារ |

| | | | |
|---|---|---|---|
| ២០- | ឧបាសក | វង់ ស៊ិន | អាចារ្យភូមិពេជសារ |
| ២១- | ឧបាសក | ឥន ភន | អាចារ្យភូមិពេជសារ |
| ២២- | ឧបាសក | អ៊ុម ជួប | អាចារ្យភូមិពេជសារ |
| ២៣- | ឧបាសក | ហ៊ួ កន | អាចារ្យភូមិពេជសារ |
| ២៤- | ឧបាសក | គាំ ជន | អាចារ្យភូមិពេជសារ |
| ២៥- | ឧបាសក | កែវ ប៊ិន | អាចារ្យភូមិពេជសារ |
| ២៦- | ឧបាសក | នៀវ ហ៊ុំ | អាចារ្យភូមិពេជសារ |
| ២៧- | ឧបាសក | អ៊ុង យុង | អាចារ្យភូមិពេជសារ |
| ២៨- | ឧបាសក | វង់ សន | អាចារ្យភូមិអង្គុញ |
| ២៩- | ឧបាសក | សេក សេម | អាចារ្យភូមិអង្គុញ |
| ៣០- | លោក | អ៊ុន ថាន់ | មេភូមិពេជសារ |
| ៣១- | ឧបាសក | ញ៉ាង់ ញូន | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣២- | ឧបាសក | ផៃ ផន | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣៣- | ឧបាសក | លិត ខេង | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣៤- | ឧបាសក | ប៉ុន ឯយ | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣៥- | ឧបាសក | កែន វ៉ាន | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣៦- | ឧបាសក | អ៊ុត ស៊ឹម | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣៧- | ឧបាសក | ឃឹម ជិ | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣៨- | ឧបាសក | សែម សាត | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៣៩- | ឧបាសក | ឈឹម ក | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៤០- | ឧបាសក | សែម សាំង | គណៈកម្មការវត្តសំរោងវ័ត្ន |
| ៤១- | ឧបាសក | ទិម ចន្ថា | គណៈកម្មការវត្តសំរោងវ័ត្ន |

| | | | |
|---|---|---|---|
| ៤២- | ឧបាសក | សឹម ផល | គណៈកម្មការវត្តសំរោងវ័ត្ត |
| ៤៣- | ឧបាសិកា | ស៊ុន ស៊ីម | សប្បុរសជនខេត្តតាកែវ |
| ៤៤- | ឧបាសក | ម៉ី ស៊ុម | អាចារ្យភូមិពោន |
| ៤៥- | ឧបាសក | ឡឹក ចក់ | អាចារ្យភូមិពោន |
| ៤៦- | ឧបាសក | ខៀវ វ៉ាន់ | អាចារ្យភូមិពោធិ |
| ៤៧- | ឧបាសក | សៀង សុត | អាចារ្យភូមិពោធិ |
| ៤៨- | ឧបាសក | ដួង ផង | អាចារ្យភូមិពោធិ |
| ៤៩- | ឧបាសក | ថុន ដុច | អាចារ្យភូមិពោធិ |
| ៥០- | ឧបាសក | អ៊ុន ស៊ិន | អាចារ្យភូមិពោធិ |
| ៥១- | ឧបាសក | នួន ផែន | អាចារ្យភូមិពោធិ |
| ៥២- | ឧបាសក | ស ណាយ | អាចារ្យភូមិជន្ទល់មេឃ |
| ៥៣- | ឧបាសក | អោម ផេន | អាចារ្យភូមិជន្ទល់មេឃ |
| ៥៤- | ឧបាសក | ញាណ ទន | អាចារ្យភូមិជន្ទល់មេឃ |
| ៥៥- | ឧបាសក | ស យ៉ាត | អាចារ្យភូមិជន្ទល់មេឃ |
| ៥៦- | ឧបាសក | កែវ ឡាយ | អាចារ្យភូមិជន្ទល់មេឃ |
| ៥៧- | ឧបាសក | ហ៊ិន នាង | អាចារ្យភូមិជន្ទល់មេឃ |
| ៥៨- | ឧបាសក | មុំ អេប | អាចារ្យភូមិជន្ទល់មេឃ |
| ៥៩- | ឧបាសក | សួន ស៊ីម | អាចារ្យភូមិជន្ទល់មេឃ |
| ៦០- | ឧបាសក | គុង ប៊ុន | អាចារ្យភូមិជន្ទល់មេឃ |
| ៦១- | ឧបាសក | ផែង ស៊ីម | អាចារ្យភូមិជន្ទល់មេឃ |
| ៦២- | ឧបាសក | ង៉េន ឆាន់ | អាចារ្យភូមិស្លែង |
| ៦៣- | ឧបាសក | អ៊ុង ងយ | អាចារ្យភូមិស្លែង |

| | | | |
|---|---|---|---|
| ៦៤- | ឧបាសក | អ៊ិន អេន | អាចារ្យភូមិស្លែង |
| ៦៥- | ឧបាសក | ហាង់ ដុក | អាចារ្យភូមិស្លែង |
| ៦៦- | ឧបាសក | សាញ់ កន | អាចារ្យភូមិស្លែង |
| ៦៧- | ឧបាសក | សៀន សុត | អាចារ្យភូមិស្លែង |
| ៦៨- | ឧបាសក | វ៉ា ឌី | អាចារ្យភូមិស្លែង |
| ៦៩- | ឧបាសក | អួន ឯន | អាចារ្យភូមិតាមោក |
| ៧០- | ឧបាសក | នួន អន្ទូង | អាចារ្យភូមិតាមោក |
| ៧១- | ឧបាសក | នួន ប៉ែត | អាចារ្យភូមិតាមោក |
| ៧២- | ឧបាសក | ហែល ឈិន | អាចារ្យភូមិតាមោក |
| ៧៣- | លោក | អេង ភីរុន | សប្បុរសជនខេត្តតាកែវ |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តតាកែវ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១១ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២០៥ សហវ.ប្រក

# ប្រកាស

# ស្តីពី

# ការបង្កើតក្រុមដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តយុទ្ធសាស្ត្រនានារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញប្រកាសលេខ ១៤៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសារាចរលេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីវិធាននិងនីតិវិធីនៃការរៀបចំការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ៧៧៦ សហវ.ប្រក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់និងទំនើបកម្មគយ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១.-**

បង្កើតក្រុមដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តយុទ្ធសាស្ត្រនានារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **គុណ ញឹម** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២. លោក **ផា សេងទើង** | អគ្គនាយករង | អនុប្រធាន |
| ៣. លោកស្រី **ហេង សំអូន** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **កែវ សុខឃាង** | អគ្គនាយករង | អនុប្រធាន |
| ៥. លោក **សែ សុឃន** | អគ្គនាយករង | អនុប្រធាន |
| ៦. លោក **កើត សុធ្ធារ៉ា** | អគ្គនាយករង | អនុប្រធាន |
| ៧. លោក **គាំ ច័ន្ទកុសល** | ប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៨. លោក **ទូ វណ្ណា** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក | សមាជិក |
| ៩. លោក **សុខ សុចិន្ដា** | ប្រធាននាយកដ្ឋានផែនការនិងបច្ចេកទេស | សមាជិក |
| ១០. លោក **ម៉ូរ ម៉ុនណារ៉ា** | ប្រធាននាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១១. លោក **ស្រេង សំណាង** | ប្រធាននាយកដ្ឋានសវនកម្មគយ | សមាជិក |
| ១២. លោក **ម៉ុន ជីម** | ប្រធាននាយកដ្ឋានរបបគយ | សមាជិក |
| ១៣. លោក **សុខ សុដារ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ | សមាជិក |

| | | |
|---|---|---|
| ១៤. លោក **ឈន ទឿន** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | សមាជិក |
| ១៥. បណ្ឌិត **សង់ ស៊ុណាទិត្យ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ | សមាជិក |
| ១៦. លោក **តិន សុតារក្ស** | ប្រធាននាយកដ្ឋានគ្រប់គ្រងការនាំចេញ | សមាជិក |
| ១៧. លោក **ថោង សុខារិទ្ធ** | នាយកសាលាជាតិគយ | សមាជិក |
| ១៨. លោក **សុខ ឫទ្ធី** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក | សមាជិក |
| ១៩. ការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ | | លេខាធិការ |
| ២០. ការិយាល័យផែនការនិងគោលនយោបាយគយ | | លេខាធិការ |

**ប្រការ ២.-**

ក្រុមដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តយុទ្ធសាស្ត្រនានា របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានភារកិច្ចដូចតទៅ៖

- កំណត់ចក្ខុវិស័យ បេសកកម្ម និងគោលដៅការងារជាយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយអនុលោមតាមយុទ្ធសាស្ត្រកៀរគរចំណូល និងផែនការយុទ្ធសាស្ត្រផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា
- ដឹកនាំកសាងផែនការសកម្មភាពនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យុទ្ធសាស្ត្រនានា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- រៀបចំអនុក្រុមការងារតាមតម្រូវការជាក់ស្តែង និងសម្របសម្រួលការអនុវត្តផែនការសកម្មភាពនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រនានា
- ផ្តល់មតិទេសក៍ក្នុងការកំណត់យន្តការតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រនានា
- ស្វែងរក និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរជំនួយសម្រាប់គាំទ្រការកសាងនិងអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រនានា
- ពិនិត្យសម្រេចលើភាពចាំបាច់ក្នុងការកែសម្រួលផែនការសកម្មភាពនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រនានា
- រៀបចំរបាយការណ៍វឌ្ឍនភាពជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣៨៧......................

ថ្ងៃ.............................. ខែ.................... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..........ខែ.............ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ២២២២/២១ គ.វ.ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ និងគ្រឿងបន្ទាប់បន្សំកាបូប របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ និងគ្រឿងបន្ទាប់បន្សំកាបូប ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ហ្គែននី វីន ប៊ែក (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ហ្គែននី វីន ប៊ែក (ខេមបូឌា) ឯ.ក **(GIANNI VINCE BAGS (CAMBODIA) CO., LTD.)** តំណាងដោយលោក **BU, DINGMING** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ EE6030319 ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ បង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ និងគ្រឿងបន្ទាប់បន្សំកាបូប ដែលមានទីតាំងស្ថិតនៅភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| កាបូបគ្រប់ប្រភេទ និងគ្រឿងបន្ទាប់បន្សំកាបូប | ១៥១២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតកាបូបគ្រប់ប្រភេទ និងគ្រឿងបន្ទាប់បន្សំកាបូប ហ្គេននី វីនប៊ែក (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១០៖</u>** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១១៖</u>** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១២៖</u>** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**<u>ប្រការ១៣៖</u>** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**<u>ប្រការ១៤៖</u>** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**<u>ប្រការ១៥៖</u>** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**<u>ចម្លងជូន៖</u>**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តកណ្តាល
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល
- -រដ្ឋបាលស្រុកអង្គស្នួល
- -រដ្ឋបាលឃុំដំណាក់អំពិល

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៤៩ រថ.អប្រក.ប្រក.

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ

លេខ ០១៤៩ រថ.អប្រក.លអ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាព សម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់លោក **កាន់ ណាន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈមានស្លាកយីហោឈ្មោះ **ស្ថានីយសារីម៉ិច ជំរីស** ស្ថិតនៅភូមិកាឡោមភ្លុក ឃុំព្រៃស្វាយ ស្រុកមោងឬស្សី ខេត្តបាត់ដំបង របស់លោក **កាន់ ណាន (ម្ចាស់ស្ថានីយ)**។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរខេត្តបាត់ដំបង
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងឧស្ម័នឥន្ធនៈគួរមានចំណុះមិនលើសពី ១០ តោន

២. ពោងឧស្ម័នឥន្ធនៈមិនត្រូវមានប្រក់ដំបូល និងជញ្ជាំងធ្វើពីស័ង្កសី

៣. ត្រូវរៀបចំរបងសំណាញ់ដែកក្រឡាធំ ឬ ចម្រឹងដែកការពារព័ទ្ធជុំវិញពោងឧស្ម័នឥន្ធនៈដាក់លើដី និងដែលអាចឱ្យខ្យល់បក់ផាត់បានល្អ



៨៤

៤. ពោងប្រេងឥន្ធនៈមួយត្រូវមានបំពង់ខ្យល់មួយសម្រាប់សម្រួលលំនឹងសម្ពាធនៃចំហាយប្រេងនៅក្នុងពោងជាមួយសម្ពាធបរិយាកាស

៥. ចម្ងាយពីទូចាក់ប្រេងឥន្ធនៈទៅទូចាក់ឧស្ម័នត្រូវមានប្រវែងអប្បបរមា ៧ ម៉ែត្រ

៦. ទូចាក់ប្រេងឥន្ធនៈត្រូវមានបំពាក់គន្លឹះអាសន្ន

៧. ទុយោចាក់ប្រេងមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ

៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹងប្រេង និងទឹក

៩. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ

១០. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។



៥៤

**ប្រការ១១.**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០១៤៩.រ.វ.អធក.ណអ........ចុះថ្ងៃទី..........០៧..........ខែ.....កុម្ភៈ......ឆ្នាំ២០២១..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ..០១៤៩.រ.វ.អធក.ណអ ចុះថ្ងៃទី......០៧....ខែ.....កុម្ភៈ.......ឆ្នាំ២០២១..នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តបាត់ដំបង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.អង្គារ..៨រោច.ខែ..មាឃ......ឆ្នាំជូត..ទោស័ក.ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...០៧.ខែ...កុម្ភៈ..ឆ្នាំ២០២១.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ សែម

**កន្លែងទទួល:**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -សាលាខេត្តបាត់ដំបង
- -ដូចប្រការ១៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៥០ រថ.អប្រក.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ

លេខ ០១៥០ រថ.អប្រក.លអ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ របស់លោកស្រី **ហ៊ឹម វណ្ណា**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោឈ្មោះ **សារីម៉ិច អូរតាគី** ស្ថិតនៅភូមិអូរតាគី ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង របស់លោកស្រី **ហ៊ឹម វណ្ណា (ម្ចាស់ស្ថានីយ)**។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីរាជធានី/ខេត្តបាត់ដំបង
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងឧស្ម័នឥន្ធនៈគួរមានចំណុះមិនលើសពី ១០ តោន

២. ត្រូវរៀបចំរបងសំណាញ់ដែកក្រឡាធំ ឬ ចម្រឹងដែកការពារព័ទ្ធជុំវិញពោងឧស្ម័នឥន្ធនៈដាក់លើដី ដែលអាចឱ្យខ្យល់បក់ផាត់បានល្អ

៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងបានតែមួយប្រភេទប៉ុណ្ណោះ
៤. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ
៥. ត្រូវបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ និងគន្លឹះអាសន្នរួម
៦. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៧. ត្រូវរៀបចំស្លាកសញ្ញាបម្រាមឱ្យបានគ្រប់គ្រាន់
៨. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៩. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១០. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ...០១៩០.៤៥.អបេក.លអ............ចុះថ្ងៃទី....០២..............ខែ...កុម្ភៈ.......ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០១៩០.៤៥.អបេក.លអ ចុះថ្ងៃទី..០២........ខែ....កុម្ភៈ.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តបាត់ដំបង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.អង្គារ...៦រោច.ខែ....មាឃ.....ឆ្នាំជូត..ទោស័ក.ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០២..ខែ..កុម្ភៈ...ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

ស៊ុយ-សែម

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :០៨៤៨ អយក.បុគ្គល/២១

# ប្រកាស

ស្តីពី

ការផ្លាស់មន្ត្រីរាជការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមលិខិតលេខ ២៣៩១ មស.គ្ររ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្លាស់លោក **សរ សិនិរ៉ា** អត្តលេខ ១៧៩១៧០០០៨៧ ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល បច្ចុប្បន្នជាមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅនាយកដ្ឋានកិច្ចការបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ក្នុងក្របខណ្ឌក្រសួងយុត្តិធម៌ ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ២ .-**

ប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់សាមីខ្លួន ត្រូវបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីបញ្ជីបើកប្រាក់របស់អង្គភាពដើម។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៣ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី